គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY

លេខ ០៦២៦/១១ គ.ស.ម

បំរើ ការពារ កសាង

# **សេចក្ដីអំពាវនាវ**

ក្នុងនាម **គណបក្សសិទ្ធិមនុស្ស** និងក្នុងនាមខ្ញុំព្រះករុណា ខ្ញុំបាទជាប្រធានគណបក្សសិទ្ធិមនុស្ស ខ្ញុំព្រះករុណា ខ្ញុំបាទសូមអំពាវនាវចំពោះបងប្អូនជនរួមជាតិខ្មែរទាំងអស់ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ សូមមេត្តាទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅក្នុងមូលដ្ឋានឃុំ-សង្កាត់របស់ខ្លួនចាប់តាំងពី ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ខ្ញុំព្រះករុណា ខ្ញុំបាទយល់ឃើញថា វាសនាអនាគតរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋយើង ត្រូវតែប្រជាពលរដ្ឋខ្មែរទាំងអស់គ្នាជាអ្នកចូលរួមកំណត់ដោយខ្លួនឯង តាមរយៈការប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួន ។ ក្នុងសង្គមប្រជាធិបតេយ្យពិតប្រាកដប្រជាពលរដ្ឋជាម្ចាស់អំណាច ។ ប្រជាពលរដ្ឋអាចធ្វើជាម្ចាស់អំណាច បានលុះត្រាតែប្រជាពលរដ្ឋអាចនឹងហ៊ានប្រើប្រាស់សិទ្ធិរបស់ខ្លួន ។ សិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំគឺជា សិទ្ធិនយោបាយដែលប្រជាពលរដ្ឋខ្មែរត្រូវមាន និងរដ្ឋាភិបាលត្រូវធានាឲ្យមាន ។ ក៏ប៉ុន្តែដើម្បីឲ្យប្រជាពលរដ្ឋអាចមានសិទ្ធិបោះឆ្នោតជ្រើសរើសអ្នកតំណាងខ្លួនបាន លុះត្រាតែប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោត ។

អាស្រ័យហេតុនេះខ្ញុំព្រះករុណា ខ្ញុំបាទ ៖

1- សូមឲ្យបងប្អូនរួមជាតិខ្មែរមេត្តាលះបង់ពេលវេលា តស៊ូពុះពារធ្វើយ៉ាងណាអញ្ជើញទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឲ្យបានតាមពេលវេលាកំណត់ខាងលើនេះ ដើម្បីទទួលបានសិទ្ធិបោះឆ្នោត ។

2- សូមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអាជ្ញាធររាជរដ្ឋាភិបាលទាំងអស់ដែលមានសមត្ថកិច្ចក្នុងការងារចុះឈ្មោះបោះឆ្នោតនេះ សូមមេត្តាបង្កលក្ខណៈងាយស្រួលដើម្បីធានាឲ្យប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំ ឡើងអាចពិនិត្យ និងចុះឈ្មោះបោះឆ្នោតបាន ។ សូមកុំរើសអើង ឬប្រើល្បិចកលនយោបាយទុច្ចរិតណាមួយឲ្យប៉ះពាល់ដល់សិទ្ធិ បោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរ ។ ជាពិសេសកុំផ្ដល់សិទ្ធិឲ្យជនបរទេសមកសម្រេចវាសនាប្រទេសខ្មែរ ជំនួសខ្មែរគ្រាន់តែ ដើម្បីគណបក្សខ្លួនឈ្នះឆ្នោតតែប៉ុណ្ណោះ ។ សូមឲ្យមានមនសិការជាតិខ្លួនឯងផង ។

3- សូមឲ្យសកម្មជន និងអ្នកគាំទ្រគណបក្សសិទ្ធិមនុស្ស នៅតាមមូលដ្ឋាននានាមេត្តាលើកទឹកចិត្តដល់ប្រជាពលរដ្ឋខ្មែរដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ឲ្យបានយល់ពីសារៈសំខាន់នៃការបោះឆ្នោត ឲ្យគាត់អញ្ជើញទៅពិនិត្យឈ្មោះ និងចុះឈ្មោះ បោះឆ្នោត និងសូមឲ្យសកម្មជនគណបក្សសិទ្ធិមនុស្ស យកចិត្តទុកដាក់តាមដានសង្កេតការណ៍ និងតវ៉ានូវភាពមិនប្រក្រតីទាំងឡាយក្នុងការពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតនេះដោយការលះបង់ខ្ពស់ ។

សូមអញ្ជើញទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១

**ប្រធានគណបក្សសិទ្ធិមនុស្ស**

HUMAN RIGHTS PARTY

**កឹម សុខា**

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 - http://www.hrpcambodia.info - hrpcambodia@yahoo.com